**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៨៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស ដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១៧១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- យោងតាមសំណើប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួន សម្រាប់អនុវត្តមុខងារជាជម្រើសរបស់ខ្លួន សំដៅលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងសមធម៌ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីគោលការណ៍ នីតិវិធី និងធនធានសម្រាប់ការគ្រប់គ្រងការចាត់ចែង និងការអនុវត្តនូវមុខងារជាជម្រើសរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តនៅគ្រប់ថ្នាក់រដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសទាំងឡាយណា ដែលមិនស្ថិតនៅក្រោមអាណត្តិនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល ឬមុខងារទាំងឡាយដែលស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា ហើយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាពុំជំទាស់ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងអនុវត្តនូវមុខងារទាំងនោះ។

អនុក្រឹត្យនេះ មិនគ្របដណ្តប់ទៅលើមុខងារជាជម្រើសដែលរដ្ឋបាលថ្នាក់ក្រោមជាតិបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តបន្តពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល បន្ទាប់ពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលបានផ្ទេរមុខងារទាំងនេះឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

**មាត្រា ៤.-**

វាក្យសព្ទនៅក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ ៖

- **មុខងារ** សំដៅដល់អំពើ ឬសកម្មភាពដែលរាប់បញ្ចូលទាំងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងៗទៀត។
- **មុខងារជាជម្រើស** សំដៅដល់មុខងារទាំងឡាយដែលផ្តួចផ្តើមជ្រើសរើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងក្របខ័ណ្ឌនៃអនុក្រឹត្យនេះ។ មុខងារជាជម្រើសរួមមាន ៖
  + មុខងារទាំងឡាយដែលមិនស្ថិតនៅក្រោមអាណត្តិនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និង
  + មុខងារទាំងឡាយដែលស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល ប៉ុន្តែក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធពុំជំទាស់ចំពោះក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស និងការអនុវត្តនូវមុខងារទាំងនោះ។

## ជំពូកទី២

## គោលការណ៍

**មាត្រា ៥.-**

ការជ្រើសរើសមុខងារជាជម្រើសរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តផ្អែកតាមគោលការណ៍ដូចខាងក្រោម ៖

- មុខងារដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមានមិនហាមឃាត់
- មុខងារដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងារដែលអាចគ្រប់គ្រង និងអនុវត្តបានប្រកបដោយប្រសិទ្ធភាព ផ្អែកតាមលទ្ធភាព និងធនធានរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងារដែលបម្រើ ឬផ្តល់ផលប្រយោជន៍ជាចម្បងដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

- មុខងារដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ ឬអាទិភាពនៃមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជាពិសេសតម្រូវការរបស់ស្ត្រី យុវជន កុមារ និងជនងាយរងគ្រោះ។

**មាត្រា ៦.-**

បទដ្ឋាន នីតិវិធី និងធនធាន សម្រាប់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស ត្រូវសម្រេចដោយឆន្ទានុសិទ្ធិផ្ទាល់របស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

**មាត្រា ៧.-**

ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស ត្រូវផ្អែកលើគោលការណ៍ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ការពិគ្រោះយោបល់ ការចូលរួម និងសមធម៌។

## ជំពូកទី៣

## នីតិវិធីនៃការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស

**មាត្រា ៨.-**

មុខងារជាជម្រើសណាមួយ ឬមួយចំនួន ដែលក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានបំណងជ្រើសរើសយកមកអនុវត្ត ចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលសាមីនីមួយៗ។

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើការកែសម្រួលនូវកម្មវិធីវិនិយោគរបស់ខ្លួន ដើម្បីដាក់បញ្ចូលនូវមុខងារជាជម្រើសថ្មី ឬមុខងារជាជម្រើសដែលត្រូវកែសម្រួល ដោយផ្អែកទៅលើសំណូមពរ និងតម្រូវការចាំបាច់របស់មូលដ្ឋាន។

**មាត្រា ៩.-**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចផ្តួចផ្តើមជ្រើសរើសមុខងារជាជម្រើសមកអនុវត្តដោយផ្អែកលើតម្រូវការរបស់ប្រជាពលរដ្ឋ ឬអាទិភាពនៃមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងផ្អែកទៅតាមសមត្ថភាពផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុដែលខ្លួនមាន។

ក្នុងការជ្រើសរើសមុខងារជាជម្រើស ក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទដូចគ្នា និងឬប្រភេទផ្សេងគ្នាដែលពាក់ព័ន្ធតាមការចាំបាច់។

ការសម្រេចយកមុខងារជាជម្រើសណាមួយឬមួយចំនួនមកអនុវត្តត្រូវមានការអនុម័តពីក្រុមប្រឹក្សា។

ចំពោះការសម្រេចយកមុខងារជាជម្រើសណាមួយ ឬមួយចំនួនដែលស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួល និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធទាំងនោះ មុននឹងក្រុមប្រឹក្សាអនុម័ត។

**មាត្រា ១០.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ អាចធ្វើការជំទាស់ចំពោះមុខងារ ដែលស្ថិតនៅក្រោមអាណត្តិរបស់ខ្លួន ដែលក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិបានជ្រើសរើស។ ការជំទាស់នេះ ត្រូវធ្វើឡើងជាលាយ

លក្ខណ៍អក្សរ ក្នុងអំឡុងពេលនៃដំណើរការកសាង ឬការកែសម្រួលផែនការអភិវឌ្ឍន៍ ឬកម្មវិធីវិនិយោគ។

ការជំទាស់របស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ អាចធ្វើឡើងក្នុងករណី ៖

- បញ្ហាសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស
- មានភាពគ្រួតស៊ីគ្នាជាមួយនឹងផែនការរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត។

**មាត្រា ១១.-**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស ៖

- ដោយខ្លួនឯងផ្ទាល់ ឬ
- ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ឬក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ ឬ
- ដោយសហការជាមួយផ្នែកឯកជន ឬសង្គមស៊ីវិល ឬអ្នកពាក់ព័ន្ធនានា។

**មាត្រា ១២.-**

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនត្រូវជានាអនុវត្តនូវមុខងារជាជម្រើសដែលបានអនុម័តដោយក្រុមប្រឹក្សាឱ្យមានប្រសិទ្ធភាព។

**មាត្រា ១៣.-**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិកែសម្រួល ឬបញ្ចប់នូវមុខងារជាជម្រើសដែលខ្លួនបានជ្រើសរើសក្នុងការអនុវត្ត។

## ជំពូកទី៤

## ធនធានសម្រាប់អនុវត្តមុខងារជាជម្រើស

**មាត្រា ១៤.-**

ក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តនូវមុខងារជាជម្រើស ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចប្រើប្រាស់ធនធានផ្ទាល់របស់ខ្លួន អំណោយដែលបានមកពីប្រភពខាងក្នុង និងខាងក្រៅដែនសមត្ថកិច្ចរបស់ខ្លួន និងឬចំណូលពីប្រភពផ្សេងទៀតដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តអនុញ្ញាត។

**មាត្រា ១៥.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ អាចប្រមូលកម្រៃពីការប្រើប្រាស់សេវា ដែលពាក់ព័ន្ធនឹងមុខងារជាជម្រើសរបស់ខ្លួន។

ចំណូលដែលប្រមូលបានពីការផ្តល់សេវាដែលពាក់ព័ន្ធនឹងមុខងារជាជម្រើស ជាចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយចំណូលនេះអាចប្រើប្រាស់សម្រាប់រ៉ាប់រងលើការចំណាយមួយផ្នែក ឬទាំងស្រុងនៃការផ្តល់សេវាទាំងនោះ។

តារាងតម្លៃសម្រាប់ការប្រមូលចំណូលពីការប្រើប្រាស់សេវា ដែលពាក់ព័ន្ធនឹងមុខងារជាជម្រើស ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១៦.-**

ការរៀបចំផែនការ ការរៀបចំគម្រោងថវិកា និងនីតិវិធីលទ្ធកម្មពាក់ព័ន្ធនឹងមុខងារជាជម្រើស ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមលិខិតបទដ្ឋាន និងសេចក្តីណែនាំស្តីពីការរៀបចំផែនការ ការរៀបចំគម្រោងថវិកា និងនីតិវិធីលទ្ធកម្មជាធរមាន លើកលែងតែមានលិខិតបទដ្ឋានដោយឡែកសម្រាប់អនុវត្តចំពោះមុខងារជាជម្រើស។

## ជំពូកទី៥

## ការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

**មាត្រា ១៧.-**

ដើម្បីធានាឱ្យការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសប្រកបដោយប្រសិទ្ធភាព គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការគាំទ្របច្ចេកទេស សមត្ថភាព និងមធ្យោបាយចាំបាច់ផ្សេងៗទៀតដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១៨.-**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចាត់ចែងឱ្យមានការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃទៅលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស។

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវរាយការណ៍អំពីលទ្ធផលនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសជូនក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ១៩.-**

ក្នុងករណីចាំបាច់ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិអាចដាក់ចេញនូវឯកសារបច្ចេកទេស ដើម្បីជួយគាំទ្រដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស។

## ជំពូកទី៦

## អវសានបញ្ញត្តិ

**មាត្រា ២០.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**

**នៃព្រះរាជាណាចក្រកម្ពុជា**

សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.**

**ស ខេង**

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២១*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*